# ពិធីសម្ពោធទឹកឃ្មុំព្រៃកម្ពុជា

ផ្សារអង្គការសេដាក រួមសហការណ៍ជាមួយក្រុមការងារអនុផលព្រៃឈើកម្ពុជា សហគមន៍អ្នកយកឃ្មុំមកពីខេត្តមណ្ឌលគីរី កោះកុង ក្រចេះ និង ព្រះវិហារ និង តំណាងអាជ្ញាធរមូលដ្ឋាននៅក្នុងសហគមន៍ បានប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យារផ្គត់ផ្គង់ទឹកឃ្មុំព្រៃធម្មជាតិ នៅព្រឹកថ្ងៃអង្គារ ទី២២ ខែមិថុនា ឆ្នាំ២០១០នេះ នៅទីស្នាក់ការកណ្តាល សហគ្រាសសេដាកនៅក្នុងរាជធានីភ្នំពេញដោយមានការចូលរួមពីភ្ញៀវជាតិ និង អន្តរជាតិ ព្រមទាំងអ្នកសារពត៌មាន សរុបចំនួន ៦៥នាក់ និង ស្ថានីយទូរទស្សន៍ក្នុងស្រុកមួយចំនួនផងដែរ។




ក្នុងគោលបំណងសំខាន់នៃការរៀបចំពិធីនេះគឺដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្គត់ផ្គង់រវាងសហគមន៍អ្នកយកឃ្មុំមកពីខេត្តទាំង៤ នោះជាមួយសហគ្រាសសេដាក និង ដើម្បីចុះហត្ថលេខាលើអនុសារណៈយោគយល់មួយរវាងក្រុមការងារអនុផលព្រៃឈើកម្ពុជាជាមួយនឹងសហគ្រាសសេដាក ដើម្បីបង្កើនការសហការគ្នាជំរុញការពង្រីកយុទ្ធសាស្ត្រទីផ្សារ និងការគាំទ្រការគ្រប់គ្រងលើគុណភាពទៅកាន់សហគមន៍អ្នកប្រមូលទឹកឃ្មុំ ។ ក្នុងការចុះហត្ថលេខានេះ ផ្លាកសញ្ញា ទឹកឃ្មុំព្រៃ ក៏បានចាប់បង្ហាញជាផ្លូវការនៅថ្ងៃនោះដែរ ។

ផ្សារអង្គការសេដាកបាននាំយកទឹកឃ្មុំព្រៃពីសហគមន៍អ្នកយកឃ្មុំនៅខេត្តកោះកុងនៅក្នុងឆ្នាំ២០០៨ ប្រមាណជា១០០លីត្រ ។ មកដល់ឆ្នាំ២០១០នេះ ផ្សារអង្គការសេដាកគ្រោងនឹងទិញទឹកឃ្មុំប្រមាណជា ៤០០០លីត្រ ពីសហគមន៍អ្នកប្រមូលទឹកឃ្មុំដែលរស់នៅក្នុងខេត្តទាំង៤នោះ ។

លោក ឡាង សេងហ៊ីង នាយកគ្រប់គ្រងរបស់ផ្សារអង្គការសេដាក បានមានប្រសាសន៍ថា៖ « ផ្សារអង្គការសេដាក គាំទ្រទឹកឃ្មុំព្រៃនេះ ដោយសារវាមានលក្ខណៈសុទ្ធល្អ មានអនាម័យ ខ្ពស់ ហើយការប្រមូលត្រូវបានធ្វើឡើងដោយគោរពតាមគោលការណ៍និរន្តរភាព » ។

ក្រុមការងារអនុផលព្រៃឈើកម្ពុជាបានធ្វើការសហការណ៍ជាមួយនឹងអង្គការក្នុងស្រុកផ្សេងៗ ដើម្បីបង្កើតអោយមានបណ្តាញទឹកឃ្មុំព្រៃថ្នាក់ជាតិមួយដែលមានសមាជិករបស់ខ្លួនជាង ៥០០នាក់ មកពីខេត្តចំនួន៧។

បណ្ដាញនេះបានរៀបចំអោយមានស្តង់ដារគុណភាពតែមួយ ដែលគិតចាប់តាំងពីការប្រមូលទឹកឃ្មុំ រហូតដល់ការវេចខ្ចប់។ ស្តង់ដារគុណភាពផ្តោតសំខាន់លើភាពសុទ្ធ អនាម័យ និងនិរន្តរភាពបរិស្ថាន។ តាមរយៈស្តង់ដារនេះ ទឹកឃ្មុំដែលប្រមូលបានដោយបណ្ដាញនេះមានឈ្មោះថា ទឹកឃ្មុំព្រៃ ។

ក្រៅពីការចូលរួមរក្សានិរន្តរភាពរបស់ឃ្មុំធម្មជាតិ ការប្រមូលបែបនេះត្រូវបានចងក្រងជាសហគមន៍ ហើយសហគមន៍នេះនឹងការពារ និងត្រួតពិនិត្យព្រៃនៅក្នុងតំបន់របស់គេសំរាប់ការប្រមូលផល។ អ្នកស្រី ហ្វេមី ពិនតូ មន្ត្រីសម្របសម្រួលក្រុមការងារអនុផលព្រៃឈើនៅប្រទេសកម្ពុជាបានមានប្រសាសន៍ថា៖ « ការគាំទ្រទីផ្សារទឹកឃ្មុំព្រៃកម្ពុជាមិនត្រឹមតែធ្វើអោយអ្នកប្រើប្រាស់ទទួលបានទឹកឃ្មុំដែលមានគុណភាពខ្ពស់ និងធ្វើអោយសហគមន៍អ្នកប្រមូលទឹកឃ្មុំបង្កើនជីវភាពរបស់គេតែបុណ្ណោះទេ ថែមទាំងចូលរួមការពារព្រៃឈើរបស់កម្ពុជាផងដែរ ។» អ្នកស្រីបានបន្ថែមថា៖ « ព្រៃឈើជាង ២០ ០០០ ហិកតាត្រូវបានការពារដោយសហគមន៍អ្នកយកឃ្មុំនៅក្នុងខេត្តទាំងបួននេះ » ។




នៅក្នុងកម្មវិធីនេះយើងក៏ឃើញមានការដាក់តាំងបង្ហាញទឹកឃ្មុំមកពីខេត្តទាំងបួន ការភ្លក់សាកល្បង រួមទាំងមានការបញ្ចាំងវីដេអូស្តីពីការប្រមូលឃ្មុំផងដែរ ។ នៅក្នុងសប្តាហ៍នេះ សមាជពេញអង្គរបស់សហព័ន្ធការពារឃ្មុំកម្ពុជា និងក្រុមសហគ្រាសទឹកឃ្មុំនៅតាមសហគមន៍ ក៏នឹងធ្វើការជួបប្រជុំគ្នាដោយមានការចូលរួមពីសហគមន៍អ្នកយកឃ្មុំទាំងអស់ ព្រមទាំងសហគ្រាសសេដាកផងដែរ ដើម្បីធ្វើការសហការបន្ថែមទៀត ។ ការសហការនេះមានសារៈសំខាន់ណាស់ ក្នុងការបង្កើនសមត្ថភាពផ្គត់ផ្គង់របស់សហគមន៍ នឹងដើម្បីធ្វើអោយ ទឹកឃ្មុំព្រៃរបស់កម្ពុជាក្លាយជាទឹកឃ្មុំដែលមានគុណភាពជាកត្តាសំខាន់ ។